ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៣ លេខ ៥៥ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសម្រេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I . ឯកសារគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

០២-១២-១៩៩៥-	អនុក្រឹត្យលេខ ៨៥ អនក្រ. បក ស្តីពីការបង្កើតគណៈកម្មការជាតិសេដ្ឋកិច្ចសង្គម សំរាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP)	២២២៣
០៧-១២-១៩៩៥-	អនុក្រឹត្យលេខ ៨៦ អនក្រ. បក ស្តីពីការចេញផ្សាយក្រដាសប្រាក់ប្រភេទ ១០០,២០០ និង ៥០០ រៀល គំរូថ្មី	២២២៥
០១-១២-១៩៩៥-	អនុក្រឹត្យលេខ ១២៧ អនក្រ. កក ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២២៦
០៤-១២-១៩៩៥-	អនុក្រឹត្យលេខ ១២៨ អនក្រ. កក ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២២៧
០៦-១២-១៩៩៥-	អនុក្រឹត្យលេខ ១២៩ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២២៨
០៦-១២-១៩៩៥-	អនុក្រឹត្យលេខ ១៣០ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២២៩
០៦-១២-១៩៩៥-	អនុក្រឹត្យលេខ ១៣១ អនក្រ. តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២២៣០

២ - សេចក្ដីសម្រេច

០៥-១២-១៩៩៥-សេចក្ដីសំរេចលេខ ៨៣ សសរ ស្ដីពីការបង្កើតគណៈកម្មការ ទ្រទ្រង់ និងគណៈកម្មការរៀបចំ សំរាប់មហោស្រពអន្តរជាតិ អង្គរ «រឿងរាមកេរ្តិ៍» ២២៣៤

០៧-១២-១៩៩៥- សេចក្ដីសំរេចលេខ ៨៤ សសរ ស្ដីពីការបង្កើតគណៈកម្មាធិការ ត្រួតពិនិត្យការងារសំរាប់កម្មវិធី TA ២២៨១ យុទ្ធសាស្ត្រ នៃការ សិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ ឧតរោបនីយកម្មវិទ្យា ២២៣៧

០៨-១២-១៩៩៥- សេចក្ដីសំរេចលេខ ៨៥ សសរ ស្ដីពីការបង្កើតគណៈកម្មាធិការ ចំរុះធ្វើគំរោងសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋបារាំង ២២៣៨

II . ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០៤-១២-១៩៩៥-ប្រកាសលេខ ៤៣០ ប្រក. សហវ. ថ ស្ដីពីការបង្វែរថវិកា របស់ក្រសួងអប់រំយុវជន និង កីឡា ២២៤១

០៦-១២-១៩៩៥-ប្រកាសលេខ ៤៣៩ ប្រក. សហវ. ថ ស្ដីពីការបង្វែរថវិកា របស់ក្រសួងពត៌មាន ២២៤៣

០៧-១២-១៩៩៥-ប្រកាសលេខ ៤៤២ ប្រក. សហវ. ថ ស្ដីពីការបបង្វែរឥណទាន របស់ក្រសួងមហាផ្ទៃ ២២៤៥

០៧-១២-១៩៩៥-ប្រកាសលេខ ៤៤៣ ប្រក. សហវ. ថ ស្ដីពីការបង្វែរឥណទាន របស់ក្រសួង អប់រំ យុវជន និងកីឡា ២២៤៨

០៨-១២-១៩៩៥-ប្រកាសលេខ ៤៤៧ ប្រក.សហវ.ថ ស្តីពីការបង្វែរឥណទាន
របស់ក្រសួង អប់រំយុវជន និង កីឡា ២២៥០

២ - ឧស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

០៤-១២-១៩៩៥-ប្រកាសលេខ ៥១០ ពណ.បល.ប្រក ២២៥២
០៥-១២-១៩៩៥-ប្រកាសលេខ ៥១១ ពណ.បល.ប្រក ស្តីពីការបង្កើតគណៈ
កម្មការរបស់ក្រសួង ២២៥៥

៣ - ឧស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០១-១២-១៩៩៥-ប្រកាសលេខ ២៩២/៩៥ ពម.ប្រក អនុញ្ញាតអោយ
កាសែត «អង្គរធំ» បោះពុម្ពចេញផ្សាយ ២២៥៦
០៤-១២-១៩៩៥- ប្រកាសលេខ ២៩៣/៩៥ ពម.ប្រក អនុញ្ញាតអោយ
កាសែត «នគររាជ» បោះពុម្ពចេញផ្សាយ ២២៥៨
០៥-១២-១៩៩៥- ប្រកាសលេខ ២៩៤/៩៥ ពម.ប្រក ទទួលស្គាល់លោក
IKUO TATSUMI ជាប្រធានការិយាល័យទីភ្នាក់ងារ
សារពត៌មានជប៉ុន KYODO NEWS SERVICE ជំនួស
លោក JUN KAMIMURA ២២៥៩

៤ - ទីស្ដីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

០២–១២–១៩៩៥–ប្រកាសលេខ ១៧៨ បទ.ប្រក ស្ដីពីថ្លៃសន្ទនាទូរស័ព្ទទៅអន្ដរជាតិ ២២៦(

៥ - ទីស្ដីការក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

០៧–១២–១៩៩៥–សេចក្ដីសំរេចលេខ ២៧៨/៩៥ កធស ស្ដីពីការអនុញ្ញាតច្បាប់ អោយបើកព្រះវិហារ គឹមភឿន ពុទ្ធសាសនាមហាយាន រាជធានីភ្នំពេញ ២២៦២

០៧–១២–១៩៩៥–សេចក្ដីសំរេចលេខ ២៧៩/៩៥ កធស ស្ដីពីការអនុញ្ញាតច្បាប់ អោយបើកព្រះវិហារ ជៀង ភៀក ពុទ្ធសាសនាមហាយាន រាជធានីភ្នំពេញ ២២៦៣

០៧–១២–១៩៩៥–សេចក្ដីសំរេចលេខ ២៨០/៩៥ កធស ស្ដីពីការអនុញ្ញាតច្បាប់ អោយបើកព្រះវិហារ អាង ភៀក ពុទ្ធសាសនាមហាយាន រាជធានីភ្នំពេញ ២២៦៤

០៨–១២–១៩៩៥– សេចក្ដីសំរេចលេខ ២៨១/៩៥ កធស ស្ដីពីការអនុញ្ញាតច្បាប់ អោយថ្វាយបង្គំនិងគោរពបូជាអ្នកតាចិន ខេត្តព្រៃវែង ២២៦៦

០៨–១២–១៩៩៥– សេចក្ដីសំរេចលេខ ២៨៣/៩៥ កធស ស្ដីពីការអនុញ្ញាតច្បាប់ អោយបើកព្រះវិហារគ្រិស្ដសាសនា ក្រុមជំនុំគ្រិស្ដបរិស័ទ គណៈនិកាយសេវេនដេយអាតវេនទីស្ទ ខេត្តកណ្ដាល ២២៦៧

៦ - រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា

ប្រកាស

០២–១២–១៩៩៥–ប្រកាសលេខ ២២៨ ជស.ប្រក ស្តីពីការតែងតាំងមន្ត្រីទទួល
ខុសត្រូវការងារលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ... ២២៦៩

៧ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

០៥–១២–១៩៩៥–ប្រកាសលេខ ១១៤៤ កទប. ស្តីពីការតែងតាំងជាបណ្តោះ
អាសន្នចំពោះមន្ត្រីរាជការ នៃមន្ទីរទេសចរណ៍ ខេត្តមណ្ឌលគិរី ២២៧១
០៥–១២–១៩៩៥–ប្រកាសលេខ ១១៤៥ កទប. ស្តីពីការតែងតាំងជាបណ្តោះ
អាសន្នចំពោះមន្ត្រីរាជការ នៃមន្ទីរទេសចរណ៍ ខេត្តក្រចេះ ២២៧២
០៦–១២–១៩៩៥–ប្រកាសលេខ ១១៦០ កទប. ស្តីពីការតែងតាំងជាបណ្តោះ
អាសន្នចំពោះមន្ត្រីរាជការ ក្របខ័ណ្ឌមន្ទីរទេសចរណ៍ រាជធានី
ភ្នំពេញ ២២៧៤

I - ទីស្តីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨៥ អនក្រ.បក.

ស្តីការបង្កើតគណៈកម្មការជាតិ សេដ្ឋកិច្ចសង្គម

សំរាប់អាស៊ី និង ប៉ាស៊ីហ្វិក (ESCAP)

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆាំ ១៩៩៤
- យោងតាមសំណូមពរចាំបាច់នូវការងាររបស់អង្គការ ESCAP " Escap National Committee "
- តាមសំណើរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រី ក្រសួងសាធារណការនិងដឹកជញ្ជូន

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការមួយ មានឈ្មោះហៅថា «គណៈកម្មការជាតិសេដ្ឋកិច្ចសង្គម សំរាប់អាស៊ីនិង ប៉ាស៊ីហ្វិក (ESCAP) ។

មាត្រា ២ : គណៈកម្មការនេះ រួមមានសមាសភាពដូចខាងក្រោម ÷

១–តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន	ជាប្រធាន
២–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	ជាសមាជិក
៣–តំណាងក្រសួងទេសចរណ៍	ជាសមាជិក
៤–តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល	ជាសមាជិក
៥–តំណាងក្រសួងគ្រប់គ្រងបរិដ្ឋាន	ជាសមាជិក
៦– តំណាងក្រសួងផែនការ	ជាសមាជិក
៧ - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ជាសមាជិក
៨–តំណាងក្រសួងពាណិជ្ជកម្ម	ជាសមាជិក
៩–តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	ជាសមាជិក
១០–តំណាង ESCAP នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងបាងកក ប្រទេសថៃឡង់ដ៍	ជាសមាជិក

មាត្រា ៣ : គណៈកម្មការជាតិសេដ្ឋកិច្ចសង្គម សំរាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP)មានភារកិច្ចនឹងសម្របសម្រួលជាមួយបណ្ដាក្រសួងដែលពាក់ព័ន្ធក្នុងការប្រមូលផ្ដុំគំនិត លើកសំណូមពរណា ដែលនាំទៅដល់លើវិស័យអភិវឌ្ឍន៍ និងស្ដារឡើងវិញហេដ្ឋារចនាសម្ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា ហើយនិងតាមដានការរីកចំរើន និងសកម្មភាពរបស់អង្គការនេះ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះព្រះហស្តលេខា និងហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៨៦ អនក្រ.បក.

ស្ដីពីការចេញផ្សាយក្រដាសប្រាក់ប្រភេទ

១០០ , ២០០ និង ៥០០រៀល គំរូថ្មី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

សំរេច

មាត្រា ១ : អនុញ្ញាតអោយចេញផ្សាយ ធ្វើចរាចរ និងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវក្រដាសប្រាក់ប្រភេទ ១០០ , ២០០ , និង ៥០០រៀល គំរូថ្មី ទន្ទឹមនឹងប្រភេទប្រាក់ដែលមានចេញ ផ្សាយរួចមកហើយ ។

មាត្រា ២ : ធនាគារជាតិនៃកម្ពុជា មានភារកិច្ចប្រកាសផ្សព្វផ្សាយ អំពីលក្ខណៈពិសេសនៃក្រដាសប្រាក់ប្រភេទថ្មីនេះ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលគ្រប់ខេត្ត–ក្រុង ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ដលេខា និងត្រា	**ហត្ថលេខា និង ត្រា**
នរោត្ដម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២៧ អនក្រ.

ស្តីពីការប្រគល់មេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះអង្គការអន្តរជាតិ និងសប្បុរស ជនដែលបានបរិច្ចាគថវិកា ជួយកសាងវិស័យអប់រំ នៅរាជធានីភ្នំពេញ ដូចមានរាយនាមខាង ក្រោម ÷

១_អង្គការ ធំរ៉ែស សង្គ្រោះកុមារកម្ពុជា " REDDBANA "
ជួយឧបត្ថម្ភអស់ទឹកប្រាក់ ២០២.៥៨៦ ដុល្លារអ៊ីយអេស ។

២_អង្គការជំនួយ សូត្តូស្ហ៊ូជប៉ុន " JSRC " ជួយឧបត្ថម្ភអស់ទឹកប្រាក់ ៣២.០០០ ដុល្លារអ៊ីយអេស ។

៣_អង្គការជំនួយសង្គ្រោះអន្តរជាតិជប៉ុន " JIRAC " ជួយឧបត្ថម្ភអស់ទឹកប្រាក់ ២៤.៥៧៧ ដុល្លារអ៊ីយអេស ។

៤_បណ្ឌិត **ឆៃ មិងយូ** " TSAIMINGYU " ប្រធានសមាគមវិភាគទានអន្តរជាតិ ជួយឧបត្ថម្ភអស់ទឹកប្រាក់ ៧៥.០០០ ដុល្លារអ៊ីយអេស ។

៥_លោក ពិន ឃាង ពាណិជ្ជករនៅទីក្រុងភ្នំពេញ ជួយឧបត្ថម្ភតុសិស្សចំនួន ៦៤០តុ និង ចាក់ដីផ្លូវចូលសាលា អស់ទឹកប្រាក់ចំនួន ១០.០០០ដុល្លារអ៊ុយអេស ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះឯកឧត្តមឧត្តមសេនីយ៍ឯក **កែ គីមយ៉ាន** នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ដែលបានចំណាយធនធានផ្ទាល់ខ្លួន ធ្វើផ្លូវពីរខ្សែ ចូលវិទ្យាល័យឥន្ទ្រទេវី អស់ទឹកប្រាក់ ១២.០០០ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១២៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សកលវិទ្យាល័យភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះលោក **តាំង ពិន** ស្នាក់នៅផ្ទះ លេខ ២៩ ផ្លូវកម្ពុជាក្រោម ខ័ណ្ឌទួលគោក ដែលបានជួយចាក់ដីកែលំអធ្វើផ្លូវក្នុងបរិវេណ សកលវិទ្យាល័យភ្នំពេញ អស់ទឹកប្រាក់ ១០.០០០ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៣០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆាំ ១៩៩៤

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់សមាគមឥស្លាមកម្ពុជា

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ១ ជូនសប្បុរសជនជាជនជាតិសហភាពអារ៉ាប់ អេមេរ៉ាត ចំនួន ០២រូប ដែលបានជួយកសាងវិហារកំពង់ទ្រាមនៅ ខេត្តកំពង់ចាម អស់ទឹកប្រាក់សរុប ៦៨.០០០ដុល្លារអាមេរិក ដូចមាននាមខាងក្រោមនេះ ÷

១_លោក **អ៊ីសាពិន ឈាសៀវ អាល់សៀវកាល់**

២_លោក **ចេដ្ឋបណ្ឌិត ម៉ះម៉ូត អាម់ឌុលឡោះ កាស៊ីម**

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សមាគមឥស្លាមកម្ពុជា ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ១៣១ អនក្រ.តត.

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ ទ្រទ្រង់សមរភូមិមុខ និងបណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ចំពោះសប្បុរសជន និងក្រុមហ៊ុន ចំនួន ៤២ ដែលបានឧបត្ថម្ភថវិកាផ្ទាល់ខ្លួន សំរាប់ជួយផ្នែកសុខាភិបាល ដល់កង យោធពលខេមរភូមិន្ទ និងកងនគរបាលជាតិ ដូចមានរាយនាមខាងក្រោម ÷

ក_មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ចំពោះ ÷

១_លោកនាយកក្រុមហ៊ុន អារីស្តុង ឧបត្ថម្ភប្រាក់ ៣៦០.០០០ ដុល្លារ

២_លោកឧកញ៉ា ថេង ប៊ុនម៉ា នាយកក្រុមហ៊ុន ថៃប៊ុនរ៉ុង ឧបត្ថម្ភប្រាក់ ១០០.០០០ ដុល្លារ

៣–លោកនាយកសណ្ឋាគារហ្វូលីដេ ឧបត្ថម្ភប្រាក់ ១០០.០០០ ដុល្លារ

៤–លោកឧកញ៉ា គង់ ទ្រីវ នាយកក្រុមហ៊ុន ថ្នាំជក់កម្ពុជា ឧបត្ថម្ភប្រាក់ ៥០.០០០ ដុល្លារ

៥–លោកឧកញ៉ា កុក អាន នាយកក្រុមហ៊ុន អានកូ ឧបត្ថម្ភប្រាក់ ៥០.០០០ ដុល្លារ

៦–លោកនាយកក្រុមហ៊ុន ភាពពីម៉ិច ឧបត្ថម្ភប្រាក់ ៥០.០០០ ដុល្លារ

៧–លោកនាយកក្រុមហ៊ុន គីម ហាប់ ឧបត្ថម្ភប្រាក់ ៥០.០០០ ដុល្លារ

៨–លោក ម៉ែន សារុន នាយកក្រុមហ៊ុន ម៉ែន សារុន ឧបត្ថម្ភប្រាក់ ២០.០០០ ដុល្លារ

៩–លោក ម៉េង សេង នាយកសណ្ឋាគារ សេរ៉ាតុន ឧបត្ថម្ភប្រាក់ ២០.០០០ ដុល្លារ

១០–លោក នាយកក្រុមហ៊ុន លី ហេងហ្វ្រូប ឧបត្ថម្ភប្រាក់ ២០.០០០ ដុល្លារ

១១–លោកឧកញ៉ា ឡាយ ងី នាយកក្រុមហ៊ុន ឡាយ ងី	ឧបត្ថម្ភប្រាក់	២០.០០០ ដុល្លារ
១២–លោកនាយកក្រុមហ៊ុន ជី ម៉ិច	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
១៣–លោក ម៉ុង ឫទ្ធី នាយកក្រុមហ៊ុន ម៉ុង ឫទ្ធី	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
១៤–លោកឧកញ៉ាសុខ គង់នាយកក្រុមហ៊ុនប្រេងឥន្ធនៈសូគីម៉ិចឧបត្ថម្ភប្រាក		១០.០០០ ដុល្លារ
១៥–លោក ឡាំ យាង នាយកក្រុមហ៊ុន មិត្តភាព	ឧបត្ថម្ភប្រ[illegible]	១០.០០០ ដុល្លារ
១៦–លោក នាយកសណ្ឋាគារ ឡានម៉ាក	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
១៧–លោក គង់ ឫទ្ធី ក្លឹបយុវជន	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
១៨–លោក គុក ម៉េង ក្រុមហ៊ុន សិលាអង្គរ	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
១៩–ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
២០–អ្នកស្រី [illegible] ក្រុមហ៊ុនកាត់ដេរ	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
២១–[illegible] ក្រុមហ៊ុនយូនិក ឯកភាព	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
២២–លោកនាយកក្រុមហ៊ុន ហ្វូតត្រាក្ធ	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
២៣–លោកនាយកក្រុមហ៊ុន ឈុន ហុង	ឧបត្ថម្ភប្រាក	១០.០០០ ដុល្លារ
២៤–អ្នកស្រី ឈុន លាង នាយកក្រុមហ៊ុនវឌ្ឍនៈ	ឧបត្ថម្ភប្រាក	១០.០០០ ដុល្លារ
២៥–លោកនាយកក្រុមហ៊ុន ដួង ឈីវ	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ
២៦–ក្រុមហ៊ុនស្រាបៀរអង្គរ	ឧបត្ថម្ភប្រាក	១០.០០០ ដុល្លារ
២៧–ក្រុមហ៊ុនអន្តរជាតិ សំ លិង	ឧបត្ថម្ភប្រាក់	១០.០០០ ដុល្លារ

ខ–មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ចំពោះ ៖

១–លោកនាយកក្រុមហ៊ុន នគរសិរិទ្ធ	ឧបត្ថម្ភប្រាក់	៦.០០០ ដុល្លារ
២–លោកនាយកក្រុមហ៊ុន សាន់កូ	ឧបត្ថម្ភប្រាក	៥.០០០ ដុល្លារ
៣–លោកនាយកក្រុមហ៊ុន ម៉ាភើម៉ិចកូ	ឧបត្ថម្ភប្រាក់	៥.០០០ ដុល្លារ
៤–លោកនាយកក្រុមហ៊ុន ហាក ហ៊ី	ឧបត្ថម្ភប្រាក់	៥.០០០ ដុល្លារ
៥–លោកនាយកក្រុមហ៊ុន គួ ហ៊ុំឡុង	ឧបត្ថម្ភប្រាក់	៥.០០០ ដុល្លារ
៦–ក្រុមហ៊ុនផលិតស្រាបៀរកម្ពុជា	ឧបត្ថម្ភប្រាក់	៥.០០០ ដុល្លារ

៧-សណ្ឋាគារកាំបូឌីយ៉ាណា	[illegible]ត្ថម្ភប្រាក់	៥.០០០ ដុល្លារ

[illegible]មជាយស្ថាបនាជាតិថ្នាក់លេខ ៣ ចំពោះ ៖

១-ក្រុ[illegible] ពាណិជ្ជកម្ម	ឧបត្ថម្ភប្រាក់	២.០០០ ដុល្លារ
២-ក្រុ[illegible]ន (SHELL)	ឧបត្ថម្ភប្រាក់	២.០០០ ដុល្លារ
៣-ធនាគារបាងកក ចំកាត់«មហាជន » សាខាភ្នំពេញ	ឧបត្ថម្ភប្រា[illegible]	១.០០០ ដុល្លារ
៤-ធនាគារក្រុងថៃ ចំកាត់«មហាជន » សាខាភ្នំពេញ	ឧបត្ថម្ភប្រាក់	១.០០០ ដុល្លារ
៥-ធនាគារកសិករថៃ ចំកាត់«មហាជន » សាខាភ្នំពេញ	ឧបត្ថម្ភប្រាក់	១.០០០ ដុល្លារ
៦-ធនាគារនគរហ្លួង ចំកាត់ «មហាជន» សាខាភ្នំពេញ	ឧបត្ថម្ភប្រាក់	១.០០០ ដុល្លារ
៧-ធនាគារកម្ពុជាពាណិជ្ជកម្ម ចំកាត់ ភ្នំពេញ	ឧបត្ថម្ភប្រាក់	១.០០០ ដុល្លារ
៨-ក្រុមហ៊ុន ស៊ុនស៊ីមិចកូ (SONY)	ឧបត្ថម្ភប្រាក់	១.០០០ ដុល្លារ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ.ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៨៣ សសរ

ស្តីពីការបង្កើតគណៈកម្មការទ្រទ្រង់និងគណៈកម្មការរៀបចំ

សំរាប់មហោស្រពអន្តរជាតិអង្គរ " រឿងរាមកេរ្តិ៍ ".

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស. ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញការអនុញ្ញាត របស់រាជរដ្ឋាភិបាលយល់ព្រមអោយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈរៀបចំសកម្មភាពធំៗបួន សំរាប់ឆ្នាំ ១៩៩៥ -៩៦ ដូចមានចែងក្នុងលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១១០៦ សជណ អរ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ១៩៩៥
- ផ្អែកតាមតំរូវការចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការទ្រទ្រង់ មហោស្រពអន្តរជាតិអង្គរ "រឿងរាមកេរ្តិ៍ " មួយដែលមានសមាសភាព ដូចក្រោមនេះ ÷

១-សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី ១ សហប្រធាន

២-សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ សហប្រធាន

៣–សម្តេច រាជបុត្រីព្រះរៀម **នរោត្តមបុប្ផាទេវី** សមាជិក

៤–ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិក

៥–ឯកឧត្តម **អ៊ឹង គៀត** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៦–ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៧–ឯកឧត្តម **អ៊ឹង ផន** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកអធិការកិច្ច សមាជិក

៨–ឯកឧត្តម **វណ្ណ ម៉ូលីវណ្ណ** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៩–ឯកឧត្តម **ចែម ស្ងួន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិក

១០–អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីវុឌ្ឍបាណារ៉ា** ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រី ទី ១ សមាជិក

១១–ឯកឧត្តម **ហង់ ជួន** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

១២–បណ្ដាអ្នកឧកញ៉ា ដែលស្ម័គ្រចិត្តទ្រទ្រង់មហោស្រពអន្តរជាតិ អង្គរ "រឿងរាមកេរ្តិ៍ »

ប្រការ ២ : បង្កើតគណៈកម្មការរៀបចំ មហោស្រពអន្តរជាតិអង្គរ "រឿងរាមកេរ្តិ៍" មួយដែលមានសមាសភាពដូចខាងក្រោមនេះ ÷

១–រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធាន

២–អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីវុឌ្ឍបាណារ៉ា** អនុប្រធាន

៣–ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការតំណាង ក្រសួងទេសចរណ៍ អនុប្រធាន

៤–ឯកឧត្តម អភិបាលខេត្តសៀមរាប អនុប្រធាន

៥–ឯកឧត្តម **ឆាយ ថន** អនុរដ្ឋលេខាធិការ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៦–តំណាងគណកម្មការរៀបចំបុណ្យជាតិ និងអន្តរជាតិ សមាជិក

៧–តំណាងអាកាសចរណ៍ភូមិន្ទកម្ពុជា សមាជិក

៨–តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩–ឯកឧត្តម **ម៉ែន យ៉េន** សមាជិក

១០–តំណាង ក្រសួងការពារជាតិ សមាជិក

១១–ឯកឧត្តម **សៀង ឡាប្រេស** តំណាងក្រសួងពត៌មាន សមាជិក

១២–តំណាងក្រសួង មហាផ្ទៃ សមាជិក

១៣–តំណាងក្រសួង អប់រំ យុវជន និងកីឡា សមាជិក

១៤–តំណាងក្រសួង សាធារណការ និងដឹកជញ្ជូន សមាជិក

១៥–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៦–តំណាងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ សមាជិក

១៧–តំណាង អាជ្ញាធរ អាកាសចរ ស៊ីវិល សមាជិក

១៨–តំណាង ក្រសួង សុខាភិបាល សមាជិក

១៩–ឯកឧត្តម **មីសែល ត្រាណេ** សមាជិក

ប្រការ ៣ : គណៈកម្មការរៀបចំ ដូចមានចែងក្នុងប្រការ២ មានសិទ្ធិនិងភារកិច្ចដូចតទៅ ÷

ក–តែងតាំងគណៈកម្មការប្រតិបត្តិការមួយប្រចាំការជាអចិន្ត្រៃយ៍ជូសមុខអោយគណៈកម្មការរៀបចំ

ខ–រៀបចំលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ

គ–រៀបចំអនុគណកម្មការជំនាញជាចាំបាច់មួយចំនួនដើម្បីបំរើសកម្មភាពមហោស្រព

ឃ–ចងក្រងបទបញ្ញាផ្ទៃក្នុងមួយសំរាប់គណកម្មការរៀបចំ

ប្រការ ៤ : គ្រប់ក្រសួងមន្ទីរ អង្គភាពទាំងឡាយដែលពាក់ព័ន្ធត្រូវអនុវត្តតាមស្មារតី នៃសេចក្តីសំរេចនេះ ។

ប្រការ ៥ : សេចក្តីសំរេចនេះ ចូលជាធរមានចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ រហូតដល់ពេលចប់មហោស្រពជាស្ថាពរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៨៤ សសរ.

ស្តីអំពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យការងារ

សំរាប់កម្មវិធី TA 2281 យុទ្ធសាស្ត្រនៃការសិក្សា

ស្រាវជ្រាវការអភិវឌ្ឍន៍ នគរោបនីយកម្មវិទ្យា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីការរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ដែលប្រកាសអោយ ដោយព្រះរាជក្រមលេខ ០៤ នស.៩៤ ចុះថ្ងៃទី ១០ សីហា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត.១០៩៤_៩៣ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ១៣ សសរ. ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ១៩៩៤ ស្តីពីការកែប្រែសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំទឹកដី និង គោលការណ៍នគរោបនីយកម្ម
- ផ្អែកតាមសំណូមពរចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មាធិការមួយហៅថា " គណៈកម្មាធិការត្រួតពិនិត្យការងារ ដើម្បីតាមដានដំណើរការអនុវត្តន៍ គំរោងការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី TA 2281 យុទ្ធសាស្ត្រ នៃការសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ នគរោបនីយកម្មវិទ្យា ។

គណៈកម្មាធិការនេះ មានសមាសភាពដូចតទៅ ÷

១_ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ ប្រធាន

២_តំណាងក្រសួងផែនការ សមាជិក

៣_តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៤_តំណាងគណៈកម្មាធិការរៀបចំទឹកដីនគរោបនីយកម្មនិងសំណង់រាជធានីភ្នំពេញ សមាជិក

៥_ប្រធានអនុគណៈកម្មាធិការខេត្ត_ក្រុង រៀបចំទឹកដីនគរោបនីយកម្មនិងសំណង់ សមាជិក

៦_នាយកខុទ្ទកាល័យ ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈរៀបចំទឹក ដីនគរោបនីយកម្មនិងសំណង់ លេខាធិការ

ប្រការ ២ : សមាជិកទាំងអស់នៃគណៈកម្មាធិការ ណែនាំការងារកម្មវិធី TA 2281 យុទ្ធសាស្ត្រនៃការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍន៍នគរោបនីយកម្ម គណៈកម្មាធិការ និង អនុគណៈកម្មាធិការរៀបចំទឹកដីនគរោបនីយកម្មនិងសំណង់រាជធានីភ្នំពេញខេត្ត_ក្រុង នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈរៀបចំទឹកដីនគរោបនីយកម្ម និង សំណង់ មានភារៈអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៨៥ សសរ.

ស្តីពីការបង្កើតគណៈកម្មាធិការចំរុះធ្វើតំរោងសហប្រតិបត្តិការ

រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋបារាំង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១០៩៤_៨៣របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

ប្រការ ១: បង្កើតគណៈកម្មាធិការចំរុះធ្វើគំរោងសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណ រដ្ឋបារាំង ដែលមានសមាសភាពដូចខាងក្រោម ÷

១_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	ជាប្រធាន
២_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៣_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	ជាសមាជិក
៤_តំណាងក្រសួងផែនការ	ជាសមាជិក
៥_តំណាងក្រសួងអប់រំ យុវជននិងកីឡា	ជាសមាជិក
៦_តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	ជាសមាជិក
៧_តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក
៨_តំណាងក្រសួងការពារជាតិ	ជាសមាជិក
៩_តំណាងក្រសួងសុខាភិបាល	ជាសមាជិក
១០_តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ	ជាសមាជិក
១១_តំណាងក្រសួងយុត្តិធម៌	ជាសមាជិក
១២_តំណាងក្រសួងពត៌មាន	ជាសមាជិក
១៣_តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ជាសមាជិក

១៤_តំណាងក្រសួងកសិកម្ម ជាសមាជិក
១៥_តំណាងក្រសួងទេសចរណ៍ ជាសមាជិក
១៦_តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក
១៧_តំណាងរាជធានីភ្នំពេញ ជាសមាជិក
១៨_តំណាងអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ជាសមាជិក
១៩_មន្ទីរក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លេខាធិការ

ប្រការ ២ : គណៈកម្មាធិការចំរុះធ្វើតំរោងសហប្រតិបត្តិការនេះមានភារកិច្ចពិនិត្យពិភាក្សាក្នុងការ :

- កំណត់ឡើងនូវគោលដៅជាយុទ្ធសាស្រ្តក្នុងការទំនាក់ទំនងនយោបាយសេដ្ឋកិច្ច កម្ពុជា–បារាំង
- កំណត់ឡើងនូវគោលនយោបាយសំរាប់ពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ កសាងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច និងតំរោងការជាអាទិភាពតាមផ្នែក
- កសាងកម្មវិធីធ្វើការរបស់គណៈកម្មការចំរុះ
- រៀបចំខ្លឹមសារចរចា ឯកសារ លិខិតដែលទាក់ទងដល់ការព្រមព្រៀងសំរាប់ការចុះហត្ថលេខា ទ្វេភាគី
- ត្រួតពិនិត្យតាមដានជំរុញការអនុវត្តផែនការ និងតំរោងការនីមួយៗ និងដាក់វិធានការសំរេច ធ្វើអោយសំរេចស្របតាមកិច្ចសន្យា និងកាលបរិច្ឆេទកំណត់
- ប្រមូលពត៌មាន ផ្លាស់ប្តូរពត៌មាន ធ្វើរបាយការណ៍ ។

ប្រការ ៣ : សមាជិកទាំងអស់នៃគណៈកម្មាធិការនេះ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាផ្លូវការ ។

ប្រការ ៥ : សហរដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្រ្តីក្រសួងផែនការ រដ្ឋមន្រ្តីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្រ្តីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សហរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ សហរដ្ឋមន្រ្តីក្រសួងការពារជាតិ រដ្ឋមន្រ្តីក្រសួងសុខាភិបាល រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ រដ្ឋមន្រ្តីក្រសួង

ពតិមាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រតិភូ រាជរដ្ឋាភិបាលប្រចាំទីក្រុងភ្នំពេញ ប្រធានអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ត្រូវអនុវត្តសេចក្ដីសំរេចនេះ. ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និង ត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

II - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៣០ ប្រក.សហវ.ថ

ស្ដីអំពីការបង្វែរតំណនាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាបការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានចែងក្នុងច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ២៦៣២ អយក.ផក.ហវ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងអប់រំយុវជន និង កីឡា ផ្នែកយុវជន និង កីឡា សំរាប់ ការគ្រប់គ្រងថវិកា ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទាន ដូចមានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតំរូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១				
១១	០១	០៤		ក្រដាសបោះពុម្ព និងសំភារៈការិយាល័យ	២០.០០០	–	២៥.០០០ ២.០០០	១៨.០០០
១១	០១	០៨	០១	សោហ៊ុយទទួលភ្ញៀវបរទេស	៤០.០០០	–	១.០០០	៣៩.០០០
១១	០១	១៤	០១	ការប្រឡងប្រជែងនិងការប្រឡង	៤២.០០០	–	១.០០០	៤១.០០០
១១	០២	០១	០១	សោហ៊ុយដឹកជញ្ជូន	២៨.០០០	–	១.០០០	២៧.០០០
១១	០២	០១	០៣	សោហ៊ុយស្នាក់នៅ	៦០.០០០	–	១០.០០០	៥០.០០០
១១	០២	០២	០៤	សោហ៊ុយផ្សេង ៗ	២០.០០០	–	១០.០០០	១០.០០០
				ផលប្រយោជន៍ជំពូក ១១		២៥.០០០		
១១	០២	០២	០១	សោហ៊ុយដឹកជញ្ជូន	២៥.០០០	២៥.០០០	--	៥០.០០០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

ហត្ថលេខា និង ត្រា

នាយ ចន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៣៩ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ដោយ ព្រះរាជក្រម លេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាបការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងពត៌មាន លេខ ១២២១/៩៥ ពម. ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ និងលេខ ១១៥៩/៩៥ ពម. ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងពត៌មាន សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការ បង្វែរឥណទាន ដូចមានបញ្ជាក់ខាងក្រោមនេះ

ឯកតា ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតម្រូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			106.000	
11	01	01	01	បៀវត្សស្នាក់ការរដ្ឋបាល	1.000		1.000	-
11	01	01	02	ការរៀបចំ និង ថែទាំ	150.000	-	10.000	140.000
11	01	02		ចលនវត្ថុ និង សម្ភារៈ	128.000	-	10.000	118.000
11	01	13		ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ	648.000	-	76.000	572.000
11	02	01	01	សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស	30.000	-	4.000	26.000
11	02	02	03	សោហ៊ុយស្នាក់នៅក្រៅប្រទេស	20.000		5.000	15.000
				ផលប្រយោជន៍ជំពូក ១១		106.000		
11	01	03		សោហ៊ុយគមនាគមន៍ទូរស័ព្ទ	85.000	26.000	-	111.000
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	240.000	80.000	-	320.000

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងព័ត៌មាន ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

នាយ ចន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៤២ ប្រក.សហវ.ទ

ស្ដីពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែ សម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ នស.៩៣ ចុះថ្ងៃទី ២៨ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្ដីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ ស្ដីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្ដាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្ដីពីការកែតំរូវច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងមហាផ្ទៃលេខ ១៩៤៩ លស.ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងមហាផ្ទៃ សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការ បង្វែរឥណទាន ដូចមានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតំរូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១			87.588	
11	01	01	02	ការរៀបចំ និង ថែទាំ	482.000		4.121	477.879
11	01	04		បោះពុម្ពសំភារៈការិយាល័យ	102.000		17.973	84.027
11	01	06		សន្និសិទ្ធ និង ប្រជុំ	30.000		6.922	23.078
11	01	07	01	ការថែទាំ និង ដំណើរការ	68.000		5.909	62.091
11	01	07	02	ប្រេងឥន្ធនៈ និង ប្រេងរំអិល	240.000		1.049	238.951
11	01	07	03	សោហ៊ុយជួលរថយន្ត	1.000		338	662
11	01	08	01	សោហ៊ុយទទួលភ្ញៀវបរទេស	19.000		781	18.219
11	01	08	02	សោហ៊ុយទទួលភ្ញៀវជាតិ	10.000		615	9.385
11	01	09	01	បុណ្យជាតិ និង បុណ្យប្រពៃណី	3.000		1.780	1.220
11	01	12	03	សិក្ខាសាលា ឬ កិច្ចប្រជុំ	10.000		4.055	5.945
11	01	99		ចំណាយផ្សេង ៗ	1.000		417	583
11	02	01	01	សោហ៊ុយដឹកជញ្ជូនក្នុងប្រទេស	14.000		1.473	12.527
11	02	01	02	សោហ៊ុយបេសកកម្មក្នុងប្រទេស	23.000		4.310	18.690
11	02	01	03	សោហ៊ុយស្នាក់នៅក្នុងប្រទេស	5.000		1.543	3.457
11	02	02	01	សោហ៊ុយដឹកជញ្ជូនក្រៅប្រទេស	13.000		12.464	536
11	02	02	02	សោហ៊ុយបេសកកម្មក្រៅប្រទេស	12.000		11.604	396
11	02	02	03	សោហ៊ុយស្នាក់នៅក្រៅប្រទេស	10.000		7.140	2.860
11	02	02	04	សោហ៊ុយផ្សេងៗ	8.000		5.094	2.906
				ផលប្រយោជន៍ជំពូក ១១		87.588		
11	01	14	09	ចំណាយសំរាប់អ្នកទោស	1.839.000	87.588		1.926.588

ប្រការ ២ : ឯកឧត្តមសហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៩៤៣ ប្រក.សហវ.ឌ

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស.៩៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ.ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ ស្តីពីការកែតម្រូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតម្រូវនៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ១៨៦៣ អយក.ផក.ហវ.លស. ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងអប់រំយុវជន និង កីឡា សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការបង្វែរឥណទាន ដូចមានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតម្រូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
10	04	02		ការបង្វែរពីជំពូក ១០ ភ្នាក់ងារបរទេសជាប់កិច្ចសន្យា	148.000	-	900 900	147.100
10	03	01		ផលប្រយោជន៍ជំពូក ១០ បៀវត្សមូលដ្ឋាន	-	900 900		900

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤៤៧ ប្រក.សហវ.ម

ស្តីអំពីការបង្វែរឥណទាន

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះ រាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចស.រកម.០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ៧៤ អនក្រ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន តាមជំពូកនៃច្បាប់ ស្តីពីការកែតំរូវ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ៣៣៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តា ក្រសួងតាមឥណទានចែងក្នុងច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ១៧៧១ អយក. ផក. ហវ. ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងអប់រំយុវជន និង កីឡា សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការបង្វែរឥណទាន ដូចមានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានកែតំរូវ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
				ការបង្វែរពីជំពូក ១១		-	22.400	
11	01	01	03	ទឹក	6.000		3.000	3.000
11	01	14	02	បោះពុម្ពសៀវភៅសិក្សា	90.000	-	12.400	77.600
11	01	14	04	រង្វាន់ និងលើកសរសើរ	5.000	-	5.000	-
11	01	14	05	សិក្ខាអប់រំសង្គមកិច្ច–កីឡា	2.000	-	2.000	-
				ផលប្រយោជន៍ជំពូក ១១		22.400		
11	01	09	04	បុណ្យផ្សេងៗ ទៀត	22.000	5.000	-	27.000
11	01	12	03	សិក្ខាសាលា ឬ កិច្ចប្រជុំ	6.500	10.000	-	16,500
11	02	01	03	សោហ៊ុយស្នាក់នៅ	13.000	7.400	-	20.400

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស

លេខ ៥១០ ពណ.បល.ប្រក

* * *

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ០៩ អនក្រ ចុះថ្ងៃទី ២៨ - ៤ - ៩២ ស្តីពីការកែសម្រួលមាត្រា២ ចំណុច ៩ និងមាត្រា៣ ចំណុច៧ និងចំណុច ៨ នៃអនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃ ទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធ ចាត់តាំងរបស់ក្រសួងពាណិជ្ជកម្ម

- បានឃើញប្រកាសលេខ ៣៣៥ ពណ.ពកប្រក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៤ របស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យ តាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំង ព្រះរាជាណាចក្រកម្ពុជា

សំរេច

ប្រការ១ : ទីបាត់ការកាំកុងត្រូល មានករណីយកិច្ចចាំបាច់ត្រូវតែត្រួតពិនិត្យរាល់មុខទំនិញនាំចេញ-ចូល ។ ការត្រួតពិនិត្យនេះសំដៅបញ្ជាក់លើ បរិមាណ-ទម្ងន់-គុណភាព យថាប្រភេទ-សំបករវេចខ្ចប់ ដើម្បីអោយសមស្របតាមកិច្ចសន្យាទិញ-លក់ ។

ប្រការ២ : ត្រួតពិនិត្យទំនិញអន់គុណភាព - ទំនិញផុតរយៈពេលប្រើប្រាស់ ។

ប្រការ៣ : ទទួលសំណើត្រួតពិនិត្យ ពីបណ្តាអង្គភាពដឹកជញ្ជូនអន្តរជាតិ លើការត្រួតពិនិត្យភាពស្អាត នៃ មធ្យោបាយការរៀបចំទុកដាក់ទំនិញទំនិញ ត្រូវរងនូវការខូចខាតលើមធ្យោបាយ (បើសិនមាន) ។

ប្រការ៤ : ទទួលធ្វើជាតំណាងក្នុងការត្រួតពិនិត្យទំនិញ អោយអង្គការត្រួតពិនិត្យទំនិញអន្តរជាតិ ។

ប្រការ៥ : មានសិទ្ធិចូលព្រលានយន្តហោះ-កំពង់ផែ-ស្ថានីយ៍អយស្ម័យយាន - ឡើងចុះមធ្យោបាយដឹកជញ្ជូនជាតិ អន្តរជាតិ និងចូលឃ្លាំងផ្ទុកទំនិញ ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ ។

ប្រការ៦ : ផ្តល់របាយការណ៍ និងវិក័យប័ត្រអាករត្រួតពិនិត្យ ជូនម្ចាស់ទំនិញ ម្ចាស់មធ្យោបាយ ដើម្បីជាមូលដ្ឋានដល់ភ្នាក់ងារគយ និងរដ្ឋាករក្នុងការប្រមូលពន្ធ ។ អាករត្រួតពិនិត្យត្រូវអនុវត្តតាម ប្រកាសរួមរបស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ៧ : យកគំរូទំនិញ ដើម្បីធ្វើកោសល្យវិច័យ « វិភាគនៅមន្ទីរពិសោធន៍ » តាមសមាមាត្រដែលបាន កំណត់ក្នុងលក្ខខ័ណ្ឌនៃការត្រួតពិនិត្យ ។ ពេលយកគំរូទំនិញ កាំកុងត្រូលអនុវត្តតាម លក្ខការណ៍ ដោយផ្តល់ប័ណ្ណយកគំរូអោយម្ចាស់ទំនិញ ។ ពេលវិភាគ

រួច គំរូនេះត្រូវបានតំកល់ទុករយៈពេល ពី ៣ទៅ ៦ ខែ ដើម្បីត្រៀមដល់ការតវ៉ាពីភាគីណាមួយ ។

ប្រការ៨ : ក្នុងពេលបំពេញភារកិច្ចត្រួតពិនិត្យទំនិញភ្នាក់ងារកាំកុងត្រូលមានឯកសណ្ឋាន :

-ខោ ពណ៌ទឹកប៊ិច

-អាវ ពណ៌ផ្ទៃមេឃ លើមាត់ហោប៉ៅអាវ មានសញ្ញា « CAMCONTROL »

ប្រការ៩ : ម្ចាស់ទំនិញត្រូវតែប្រកាសមុខទំនិញ «Déclaration » និងផ្តល់ឯកសារពាក់ព័ន្ធទំនិញដូចជា : កិច្ចសន្យា - អាជ្ញាប័ណ្ណ - អញ្ញត្តិប័ណ្ណ -ប័ណ្ណដឹកជញ្ជូន-គំរូ ។ ល ។ ដល់កាំកុងត្រូល ។

ប្រការ១០ : ម្ចាស់ទំនិញដែលមានទំនិញ ត្រូវរងនូវការត្រួតពិនិត្យ ត្រូវបង្កលក្ខណៈ និងផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់កាំកុងត្រូល ដូចជាកម្មករ-មធ្យោបាយ- ឧបករណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់ ដំណើរការត្រួតពិនិត្យ ដើម្បីអោយការងារនេះប្រព្រឹត្តិទៅបានស្រួល និងឆាប់រហ័ស (បើសិន ជាចាំបាច់) ។

ប្រការ១១: ចំពោះទំនិញនាំចូល ម្ចាស់ទំនិញត្រូវនាំចូលតែទំនិញណាដែលមានផ្លាកសញ្ញា-មានចុះថ្ងៃ ខែ ផលិត និងរយៈពេលផុតកំណត់នៃការប្រើប្រាស់ ។

ប្រការ១២: ទំនិញនាំចេញ ដែលមានកិច្ចសន្យា បើកាំកុងត្រូលពិនិត្យឃើញថាមិនសមស្របតាមសំណូមពរដូចក្នុងកិច្ចសន្យា ដូចជាសំបកវេចខ្ចប់ សញ្ញាសំគាល់ បរិមាណ-ទំងន់-គុណភាព យថាប្រភេទ ត្រូវជូនដំណឹងដល់ម្ចាស់ទំនិញ ដើម្បីធ្វើការកែច្នៃឡើងវិញ ។ ពេលកែច្នៃរួចហើយ កាំកុងត្រូលនឹងត្រួតពិនិត្យសារជាថ្មីម្តងទៀត ។ តែក្រោយពីការកែច្នៃទំនិញនៅតែពុំសម ស្រប ប៉ុន្តែភាគីទិញ-លក់ បានឯកភាពជាផ្លូវការដោយមានលាយល័ក្ខអក្សរ កាំកុងត្រូល នឹង ត្រួតពិនិត្យជាក់ស្តែងព្រមទាំងផ្តល់របាយការណ៍ ឬ វិញ្ញាប័នប័ត្រជូនម្ចាស់ទំនិញ ។

ប្រការ១៣ : ម្ចាស់ទំនិញត្រូវបង់អាករត្រួតពិនិត្យ ជូនកាំកុងត្រូល ក្រោយពេលទទួលបានរបាយការណ៍ ឬ វិញ្ញាប័នប័ត្រ និងវិក័យប័ត្រអាករត្រួតពិនិត្យ ។

ប្រការ១៤ : ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន :

-ភ្នាក់ងារកាំកុងត្រូលណាខ្វះស្មារតីទទួលខុសត្រូវក្នុងពេលបំពេញភារកិច្ច ។

-ជនណាដែលក្លែងវិញ្ញាប័នប័ត្រត្រួតពិនិត្យ ឬលិខិតស្នាមផ្សេងៗរបស់កាំកុងត្រូល ។

ប្រការ១៥ : បណ្តាអង្គភាពអាជីវកម្មនាំចេញ-នាំចូល ត្រូវយល់អោយបានច្បាស់លាស់នូវខ្លឹមសារដែលបានកំណត់ខាងលើ និងអនុវត្តអោយបានត្រឹមត្រូវតាមប្រកាសនេះ ។

ប្រការ១៦ : ប្រធានមន្ទីរ នាយកទីចាត់ការកាំកុងត្រូល ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ត្រូវអនុវត្តខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស

លេខ ៥១១ ពណ.បល.ប្រក

ស្តីពីការបង្កើតគណៈកម្មការរបស់ក្រសួង

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាស ភាព រាជរដ្ឋាភិបាលកម្ពុជា
- យោងស្មារតីអង្គប្រជុំប្រចាំសប្តាហ៍នាថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានពិនិត្យលើការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ១ : បង្កើតគណៈកម្មការរបស់ក្រសួងមួយ ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម **នុច សំ** អនុរដ្ឋលេខាធិការ ជាប្រធានគណៈកម្មការ

២–លោក គឹម ធឿន ប្រធាននាយកដ្ឋានគណនេយ្យ ជាអនុប្រធាន

៣–លោក អ៊ុំ សំផន អនុប្រធានមន្ទីរ ជាសមាជិក

៤–លោក ស៊ុំ សារ៉ាញ់ អនុប្រធានគណៈកម្មាធិការត្រួតពិនិត្យ ជាសមាជិក

៥–លោក តំណាងក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ជាសមាជិក

៦–លោក ខ្លិម សំអុល អនុប្រធានការិយាល័យបៀវត្ស ជាសមាជិក

៧–អ្នកស្រី អ៊ិន សរិទណ្ណា អនុប្រធានការិយាល័យហិរញ្ញកិច្ច ជាសមាជិក

៨–លោក ទ័ត ខ្លី អនុប្រធានការិយាល័យផ្គត់ផ្គង់ ជាសមាជិក

ប្រការ២ : គណៈកម្មការនេះ មានភារកិច្ច ប្រកាស ជួល លក់អចលនទ្រព្យ ដោយវាយតំលៃទាំងបរិមាណ និងគុណភាពអោយបានសមស្របក្នុងពេលជាក់ស្តែងៗ ។

ប្រការ៣ : រាល់ប្រកាសនានាពីមុនដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤ : គណៈកម្មការត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ចម ប្រសិទ្ធ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស

លេខ ២៩២/៩៥ ពម.ប្រក

អនុញ្ញាតអោយកាសែតឈ្មោះ «នគររាជ»

បោះពុម្ពចេញផ្សាយ

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី៤១

– យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការងារអភិវឌ្ឍន៍នៃវិស័យទេសចរណ៍

សម្រេច

ប្រការ ១ : តែងតាំង ÷

១–លោក **សៀ ម៉ុងជិន** ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២–លោក **ឆន ហាង** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

៣–លោក **អ៊ុម ប៊ុន** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក - ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ :

១–លោក **ស៊ុន ជា** ជាប្រធាន

២–លោក **ឈៀង សារឿន** ជាអនុប្រធាន

៣–អ្នកស្រី **ថុម សុខឃីម** ជាអនុប្រធាន

ខ - ការិយាល័យឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ :

១–លោក **ឡឹង សុខជា** ជាប្រធាន

២–លោក **ម៉ុក ម៉េងហ៊ាង** ជាអនុប្រធាន

គ - ការិយាល័យអភិវឌ្ឍន៍ធម្មជាតិ និង បណ្តុះបណ្តាលវិជ្ជាជីវៈ :

១–លោក **អ៊ុង ស៊ីយឿង** ជាប្រធាន

២–លោក **ប៊ុន ថេង** ជាអនុប្រធាន

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋាន គ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១១៦០ កទច

ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះមន្ត្រីរាជការ

និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍រាជធានីភ្នំពេញ

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងប្រកាសលេខ ០១៣ កមចប្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
- យោងលិខិតលេខ ៩៦១៩ លស ពក ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ស្តីពីសំណើពិនិត្យ និងសំរេចតែងតាំងមន្ត្រី រាជការមន្ទីរ និង ថ្នាក់ការិយាល័យសំរាប់មន្ទីរទេសចរណ៍ រាជធានីភ្នំពេញ
- យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍

សំរេច

ប្រការ ១ : តែងតាំង :

១-អ្នកស្រី ពុំ **ស៊ីចាន់** ជាប្រធានមន្ទីរ

២-លោក **ចិន សាម៉ន** ជាអនុប្រធានមន្ទីរ

៣-អ្នកស្រី **ម៉ា ឡា** ជាអនុប្រធានមន្ទីរ

ប្រការ ២ : មន្ទីរទេសចរណ៍រាជធានីភ្នំពេញ មាន ៤ ការិយាល័យ :

ក - ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ :

១-អ្នកស្រី **ខន្តី បូរ៉ាណសារ៉ែត** ជាប្រធាន

២-លោក **ប៉ែន មុនី** ជាអនុប្រធាន

ខ - ការិយាល័យឧស្សាហកម្មទេសចរណ៍ និង ផែនការអភិវឌ្ឍន៍ :

១-លោក **លឹម សិនិទ្ធ** ជាប្រធាន

២-លោក **ក្រោក គឹមមាន** ជាអនុប្រធាន

គ - ការិយាល័យអភិវឌ្ឍន៍វប្បធម៌ និង បណ្ដុះបណ្ដាល :

១-លោក **សំ ចាន់រ៉េត** ជាប្រធាន

២-អ្នកស្រី **ទ៉ាន់ ម៉ានី** ជាអនុប្រធាន

ឃ - ការិយាល័យពត៌មាន និង ផ្សព្វផ្សាយ :

១-លោក **យី យ៉េន** ជាប្រធាន

២-លោក **ស៊ុម គង់** ជាអនុប្រធាន

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ចំនួន ៣១ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋាន គ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ ៣៧ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង នាយករដ្ឋមន្ត្រីទី១ និង ទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំង រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសំណើសុំច្បាប់អនុញ្ញាត អោយបើកព្រះវិហារ អាង គៀក « ពុទ្ធសាសនា មហាយាន » រាជធានីភ្នំពេញ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកព្រះវិហារ **អាង គៀក** « ពុទ្ធសាសនា មហាយាន » ដែលមានទីតាំងមួយកន្លែង ស្ថិតនៅផ្ទះលេខ៦៥ក្រុមទី ០៣ សង្កាត់ ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ព្រះវិហារ **អាង គៀក** ត្រូវអនុញ្ញាតអោយដំណើរការផ្សព្វផ្សាយនូវ លទ្ធិសាសនា មហាយាន ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : «ព្រះវិហារ **អាង គៀក** »ត្រូវគោរពអោយបានម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា សន្យាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនានិងសណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវ សហការអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

ហឿន ចន្ទរ័ត្ន

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៥

សេចក្តីសំរេច

លេខ ២៨១/៩៥ ក.ធ.ស

« ស្តីពីការអនុញ្ញាតច្បាប់អោយថ្វាយបង្គំ

និងគោរពបូជាអ្នកតាចិន ខេត្តព្រៃវែង »

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង ទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសំណើសុំច្បាប់អនុញ្ញាត បើកកន្លែងគោរពបូជាអ្នកតាចិន ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតច្បាប់ជាគោលការណ៍ អោយមានកន្លែងគោរពបូជាអ្នកតាចិនមួយកន្លែង ដែលមានទីតាំងស្ថិតនៅរង្វង់អ្នកតាចាស់ ឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

ប្រការ ២ : ទីកន្លែងគោរពបូជាអ្នកតាចិននេះ ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយឯកសារផ្សេងៗ និងថ្វាយបង្គំ ព្រះ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ព្រះវិហារនេះត្រូវគោរពអោយបានម៉ឹងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា សឡាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិ សេរីភាពខាងជំនឿសាសនា និងសណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយ ពីសេចក្តីសំរេចនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្ត សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

ហៀង វណ្ណារិទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៥

សេចក្តីសំរេច

លេខ ២៨៣/៩៥ ក.ធ.ស

ស្តីពីការអនុញ្ញាតច្បាប់អោយបើកព្រះវិហារ

គ្រិស្តសាសនា «ក្រុមជំនុំគ្រិស្តបរិសុទ្ធគណៈនិកាយ

សេវេនដេយអាត់វេនទីស្ទ» ខេត្តកណ្តាល

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង ទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញពាក្យសុំច្បាប់អនុញ្ញាតច្បាប់ សុំបើកព្រះវិហារគ្រិស្តសាសនា «ក្រុមជំនុំគ្រិស្តបរិស័ទ គណៈនិកាយសេវេនដេយអាត់វេនទីស្ទ» ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៥

សម្រេច

ប្រការ ១ អនុញ្ញាតច្បាប់ជាគោលការណ៍អោយបើកព្រះវិហារគ្រិស្តសាសនា « ក្រុមជំនុំគ្រិស្តបរិស័ទ គណៈនិកាយសេវេនដេយអាត់វេនទីស្ទ » មួយកន្លែងស្ថិត នៅក្រុមទី ០៣ ភូមិព្រៃកស្វែង ឃុំព្រៃកស្វែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រការ ២ : វិហារគ្រិស្តសាសនា «ក្រុមជំនុំគ្រិស្តបរិស័ទគណៈនិកាយសេវេនដេយអាត់វេនទីស្ទ » ត្រូវ ផ្សព្វផ្សាយនូវលទ្ធិសាសនាគ្រិស្ត ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ព្រះវិហារគ្រិស្តសាសនា «ក្រុមជំនុំគ្រិស្តបរិស័ទគណៈនិកាយសេវេនដេយអាត់វេនទីស្ទ» ត្រូវគោរពអោយបានម៉ឺងម៉ាត់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិ ផ្សេងៗ របស់ក្រសួងធម្មការ និងសាសនា សព្វជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់សង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធត្រូវសហការអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ហត្ថលេខានិងត្រា

ហៀង វណ្ណារិទ្ធ

* * *

៦ - រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយសភា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស លេខ : ២២៨ ទជស.ប្រក

ស្តីពីការតែងតាំងមន្ត្រីទទួលខុសត្រូវការងារលទ្ធកម្មសាធារណៈ

នៃ រដ្ឋលេខាធិការដ្ឋាន ទំនាក់ទំនងជាមួយរដ្ឋសភា

* * *

រដ្ឋលេខាធិការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ ០២ ស.ន ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលប្រការអោយប្រើដោយព្រះរាជ ក្រមលេខ ០៦ សន ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤
- យោងអនុក្រឹត្យលេខ ៦០ អនក្រ,បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- យោងសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០០៦ សណន.លស ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តនីតិ[illegible] លទ្ធកម្មសាធារណៈ តាមខ្លឹមសារនៃចំណុច ៣
- យោងសេចក្តីសំរេចលេខ ០០៣ ទជស.សសរ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអង្គភាពលទ្ធកម្មសាធារណៈ នៃរដ្ឋលេខាធិការដ្ឋាន ទំនាក់ទំនងជាមួយរដ្ឋសភា

សំរេច

ប្រការ ១ : តែងតាំងសមាសភាព នៃអង្គភាពលទ្ធកម្មសាធារណៈ នៃរដ្ឋលេខាធិការដ្ឋានទំនាក់ទំនង ជាមួយរដ្ឋសភាដូចមានរាយនាមខាងក្រោម ÷

ក – ក្រុមការងារលទ្ធកម្មផ្ទាល់ :

១_លោក ញឹម សុផល នាយការិ.ផែនការ អ្នកទទួលខុសត្រូវផ្ទាល់បន្ថែមលើមុខងារបច្ចុប្បន្ន

២–លោក ម៉ែន មុីនលាង បុគ្គ–ហិរញ្ញវត្ថុ ប្រធានផ្នែក

៣–លោក នង សុខុន គណនេយ្យទូទាត់ សមាជិក

៤– លោក ទ័ម សុខា លេខាធិការ សមាជិក

ខ - ក្រុមត្រួតពិនិត្យការងារលទ្ធកម្ម :

១– លោក ឱ្យយ ហោង នាយកទ.ខ.ស ប្រធាន

២– លោក ឌុះ ទុន្ស៊ី នាយករង រដ្ឋបាល-បុគ្គលិក សមាជិក

៣– លោក កែម ផល្លា នាយករង ឯកសារ-ច្បាប់ សមាជិក

៤– លោក អ្នកបច្ចេកទេស១ រូប សមាជិក

គ-គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា

១– ឯកឧត្តម អនុរដ្ឋលេខាធិការ ទទួលបន្ទុក ប្រធាន

២– លោក ជា គង់ អគ្គនាយករង សមាជិក

៣– លោក ម៉ែត សំណាង នាយករដ្ឋបាល-បុគ្គលិក សមាជិក

៤– លោក អ៊ុក ម៉ូរី នាយកហិ.គ សមាជិក

៥– លោក ញឹម សុផល អ្នកទទួលខុសត្រូវលទ្ធកម្មផ្ទាល់ លេខាធិការ

ប្រការ ២ : សមាសភាពដូចមានរាយនាមក្នុងប្រការ ១ នៃប្រកាសនេះ មានតួនាទី ភារកិច្ចអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ ០០៣ ទជស.សសរ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥ អោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

ប្រការ ៥ : អនុរដ្ឋលេខាធិការ ,នាយកខុទ្ទកាល័យ,អគ្គនាយករង, នាយកគ្រប់នាយកដ្ឋាន និងសាមីខ្លួននៅក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

នួច កានុន

៧ - ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១១៤៤ កឧច

ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះមន្ត្រីរាជការ

នៃមន្ទីរទេសចរណ៍ ខេត្តមណ្ឌលគីរី

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងប្រកាសលេខ ៧២៧ កទច ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរទេសចរណ៍ ខេត្តមណ្ឌលគីរី
- យោងលិខិតលេខ ២២៥-៩៤ លស ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីការសំណើសុំការឯកភាពលើគំរោងរចនាសម្ព័ន្ធក្របខ័ណ្ឌ និង អង្គការលេខរបស់មន្ទីរទេសចរណ៍ ខេត្តមណ្ឌលគីរី
- យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការងារអភិវឌ្ឍន៍នៃវិស័យទេសចរណ៍

សំរេច

ប្រការ ១ : តែងតាំង ÷

១-លោក **ចន សំខិន** ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២-លោក **ឡុង ចណ្ណនី** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក - ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ :

១-លោក **ខិន សុខិមាន** ជាប្រធាន

ខ - ការិយាល័យខ្សែសង្វាក់ផលិតកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ

១-លោក ពុធ សុរិយា ជាប្រធាន

គ - ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស និង មជ្ឈមណ្ឌលវិជ្ជាជីវៈ :

១-លោក ស៊ិន សារុន ជាប្រធាន

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានគ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១១៤៥ កទច

ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះមន្ត្រីរាជការ

នៃមន្ទីរទេសចរណ៍ ខេត្តក្រចេះ

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងប្រកាសលេខ ៧២៥ កទច ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរទេសចរណ៍ ខេត្តក្រចេះ
- យោងលិខិតលេខ ៦៨ សរក្រច ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៩៥ របស់អភិបាលខេត្តក្រចេះ ស្តីពីសំណើរៀបចំរចនាសម្ព័ន្ធក្របខ័ណ្ឌមន្ត្រីរាជការមន្ទីរ ទេសចរណ៍ខេត្ត

– យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការងារអភិវឌ្ឍន៍នៃវិស័យទេសចរណ៍

សំរេច

ប្រការ ១ : តែងតាំង ÷

១–លោក **អៀ ម៉ុងរ៉េន** ជាប្រធានមន្ទីរទេសចរណ៍ខេត្ត

២–លោក **ឧង ហាង** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

៣–លោក **អ៊ឹម ប៊ុន** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្ត

ប្រការ ២ : មន្ទីរទេសចរណ៍ខេត្តមាន បីការិយាល័យ :

ក - ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ :

១–លោក **ស៊ិន ជា** ជាប្រធាន

២–លោក **ឡៀង សារឿន** ជាអនុប្រធាន

៣–អ្នកស្រី **ជួម សុខឃីម** ជាអនុប្រធាន

ខ - ការិយាល័យឧស្សាហកម្មទេសចរណ៍ ផែនការ និង ផ្សព្វផ្សាយ :

១–លោក **ឡឹង សុខជា** ជាប្រធាន

២–លោក **ម៉ុត ម៉េងហ៊ាង** ជាអនុប្រធាន

គ - ការិយាល័យអភិវឌ្ឍន៍តំបន់ និង បណ្តុះបណ្តាលវិជ្ជាជីវៈ :

១–លោក **អ៊ុង ស៊ីយឿង** ជាប្រធាន

២–លោក **ប៊ុន ថេង** ជាអនុប្រធាន

ប្រការ ៣ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋាន គ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សេរីវុឌ្ឍ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១១៦០ កនច

ស្តីពីការតែងតាំងជាបណ្ដោះអាសន្នចំពោះមន្ត្រីរាជការ និងក្របខ័ណ្ឌមន្ទីរទេសចរណ៍រាជធានីភ្នំពេញ

* * *

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងប្រកាសលេខ ០១៣ កទចប្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
- យោងលិខិតលេខ ៤៦១៩ ពរស.បត ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ស្តីពីសំណើពិនិត្យ និងសំរេចតែងតាំងមន្ត្រី រាជការមន្ទីរ និង ថ្នាក់ការិយាល័យសំរាប់មន្ទីរទេសចរណ៍ រាជធានីភ្នំពេញ
- យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការអភិវឌ្ឍវិស័យទេសចរណ៍

សំរេច

ប្រការ ១ : តែងតាំង ÷

១–អ្នកស្រី ពុំ **ស៊ីចាន់** ជាប្រធានមន្ទីរ

២–លោក **ចិន សាម៉ន** ជាអនុប្រធានមន្ទីរ

៣–អ្នកស្រី **ម៉ា ឡា** ជាអនុប្រធានមន្ទីរ

ប្រការ ២ : មន្ទីរទេសចរណ៍រាជធានីភ្នំពេញ មាន ៤ ការិយាល័យ :

ក - ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ :

១–អ្នកស្រី **ខន្តី ម៉ូរ៉ាណសារ៉េត** ជាប្រធាន

២–លោក **ម៉ែន មុនី** ជាអនុប្រធាន

ខ - ការិយាល័យខ្នាតស្តង់ដារផលិតផលទេសចរណ៍ និង ផែនការអភិវឌ្ឍន៍ :

១-លោក លឹម សិទ្ធិ ជាប្រធាន

២-លោក ម៉ោក គឹមមាន ជាអនុប្រធាន

គ - ការិយាល័យអភិវឌ្ឍន៍ធម្មជាតិ និង មណ្ឌលកម្សាន្ត :

១-លោក សំ ចាន់ឡើត ជាប្រធាន

២-អ្នកស្រី ម៉ាន់ ម៉ានី ជាអនុប្រធាន

ឃ - ការិយាល័យពត៌មាន និង ផ្សព្វផ្សាយ :

១-លោក ឃី យ៉េន ជាប្រធាន

២-លោក ស៊ុម គង់ ជាអនុប្រធាន

ប្រការ ៣ : បច្ចុប្បន្នទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការរបស់មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ចំនួន ៣១ កន្លែង ។

ប្រការ ៤ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋាន គ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វ៉េង សេរីវុឌ្ឍ

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៤៩៦ រៀល